# មេរៀនទី ៥៩៖ ព្រះយេស៊ូវធ្វើឲ្យណាថាណែលភ្ញាក់ផ្អើល

[យ៉ូហាន ១៖៤៣-៥១]

**មេរៀនសម្រាប់គ្រូ** ( *យូធូបលីង* )៖ https://youtu.be/kv3wj79aRig

**រឿងនៅក្នុងព្រះគម្ពីរសម្រាប់កុមារ៖** https://youtu.be/pTuz1mCXcR4

**គោលបំណង៖** ព្រះយេស៊ូវជ្រាបដឹងគ្រប់យ៉ាងអំពីយើងរាល់គ្នា

**ខគម្ពីរចងចាំ៖** ទំនុកដំកើង ១៣៩៖១ *"ឱព្រះយេហូវ៉ាអើយទ្រង់បានពិនិត្យមើល ហើយបានស្គាល់ទូលបង្គំផង"។*

**ចំរៀង** ( *យូធូបលីង* )៖
១.ព្រះយើងជាព្រះអស្ចារ្យ https://youtu.be/TU6HfxJXLvQ
២.ព្រះយេស៊ូវគ្រីស្ទជាព្រះអម្ចាស់ https://youtu.be/I-PzUIJ0MVo
៣.ទ្រង់ជាព្រះ https://youtu.be/JWTOzAqGcyI

## ១. អធិស្ឋាន

## ២. ចំរៀង ( *រើសចំរៀងខាងលើ១បទហើយច្រៀងជាមួយសិស្ស* )

## ៣. ល្បែងកំសាន្ត «ទស្សន៍ទាយពីចិត្តគំនិត»



សម្ភារៈដែលត្រូវការ៖ ក្រដាស ប៊ិក

១. គ្រូកាត់ក្រដាសជាមួយជ្រុងតូចល្មមសរសេរពាក្យ ដើម្បីឲ្យកុមារធ្វើកាយវិកាយតាម (យំ សើច ជិះម៉ូត ជិះកង់ ឡើងដើមឈើ ញុំាបាយ ដេក ផឹកទឹក ហែលទឹក ។ល។) ហើយកាត់ក្រដាសនោះចេញមករួចបត់វាតូចៗ

២. យើងបែងចែកកុមារជា២ក្រុម

៣. យើងរើសកុមារម្នាក់នៅក្នុងក្រុមរបស់គាត់ឡើងមកខាងមុខ ឲ្យគាត់ជ្រើសរើសក្រដាស១សន្លឹក ហើយធ្វើកាយវិកាយតាមក្រដាសនោះ ហើយឲ្យសមាជិកក្រុមនីមួយៗជាអ្នកទាយ មានពេលតែ ១នាទីទេសំរាប់ការលេងល្បែងនេះ ។ ក្រុមទីមួយលេងចប់ ក្រុមទី២លេងម្តង។

៤. បន្ទាប់មក យើងរាប់ តើក្រុមមួយណាទាយត្រូវច្រើនជាងគេ ក្រុមនោះជាអ្នកឈ្នះ។

## ៤. ការណែនាំមេរៀន

តើអ្នកនឹងមានអារម្មណ៍យ៉ាងដូចម្តេចនៅពេលដែលអ្នកបានជួបនរណាម្នាក់ដែលដឹងគ្រប់យ៉ាងអំពីអ្នក? តើអ្នកនឹងសប្បាយចិត្ត? ភ័យខ្លាច? ឬក៏ខឹង? បន្ទាប់ពីព្រះយេស៊ូវបានទទួលបុណ្យជ្រមុជទឹកតាមរយៈយ៉ូហានបាទីស្ទរួច ព្រះអង្គចាប់ផ្តើមបេសកម្មរបស់ទ្រង់ដោយការបង្រៀន ការចែកចាយព្រះបន្ទូល និងការប្រោសឲ្យជា។ ទ្រង់បានធ្វើឲ្យមនុស្សគ្រប់គ្នាមានការភ្ញាក់ផ្អើលដោយសារ ទ្រង់បានដឹងគ្រប់យ៉ាងពីមនុស្សគ្រប់គ្នា។ ទ្រង់ដឹងពីអ្នកមាន អ្នកក្រ អ្នកមានអំណាច អ្នកទន់ខ្សោយ មនុស្សចាស់ឬកូនក៏ក្មេង។

តោះសូមយើងរៀនអំពីគ្រាមួយ ដែលព្រះយេស៊ូវបានធ្វើឲ្យបុរសម្នាក់ភ្ញាក់ផ្អើល ដោយមិនត្រឹមតែស្គាល់ឈ្មោះរបស់គាត់ប៉ុណ្ណោះទេ ប៉ុន្តែទ្រង់ក៏ដឹងពីអ្វីដែលបុរសម្នាក់នោះកំពុងគិតផងដែរ។

## ៥. រឿងនៅក្នុងព្រះគម្ពីរ

ថ្ងៃមួយព្រះយេស៊ូវបានត្រាស់ហៅភីលីពឲ្យដើរតាមទ្រង់។ ភីលីពដឹងប្រាកដថានេះហើយគឺជាព្រះមេស្ស៊ី! នៅពេលដែលភីលីពបានប្រាប់ណាថាណែលថា គាត់បានរកឃើញរឿងមួយដែលលោកម៉ូសេបានសរសេរនៅក្នុងច្បាប់របស់គាត់ ហើយក៏ជាម្នាក់ដែលពួកហោរាបានសរសេរអំពីគាត់ផងដែរ ណាថាណែលមិនបានជឿលើរឿងនេះនោះទេ។ គាត់មិនជឿថា ព្រះមេស្ស៊ីនឹងមកស្រុកណាសារ៉ែតនោះទេ ពីព្រោះថានៅក្នុងព្រះគម្ពីរសញ្ញាចាស់មិនបានបញ្ជាក់ ថាព្រះមេស្ស៊ីនឹងយាងមកណាសារ៉ែតនោះទេ។ ព្រះគម្ពីរ **យ៉ូហាន ១៖៤៦** បាននិយាយថា «តែណាថាណែលនិយាយថា "តើមានអ្វីដ៏ល្អ អាចចេញពីណា សារ៉ែតមកបានឬទេ?" ណាថាណែលសួរ ភីលីពឆ្លើយឡើងថា "ចូរតាមខ្ញុំទៅមើលចុះ»។

នៅពេលដែលព្រះយេស៊ូវបានឃើញឥរិយាបថរបស់ណាថាណែល ទ្រង់បានសម្គាល់ឃើញថា ណាថា-ណែលឥតមានចិត្តឧបាយនោះទេ។ ណាថាណែលមានការភ្ញាក់ផ្អើលជាខ្លាំង។ គាត់បាន សួរទ្រង់ថាតើអ្នកស្គាល់ខ្ញុំដោយរបៀបណា។ ព្រះយេស៊ូវបានតបទៅគាត់ថា "មុនដែលភីលីពហៅមក កាលអ្នកនៅក្រោមដើមល្វានៅឡើយ នោះខ្ញុំបានឃើញអ្នកហើយ" ។ បន្ទាប់ពីឮព្រះបន្ទូលរបស់ព្រះយេស៊ូវរួចហើយ ណាថាណែលដឹងថា ព្រះយេស៊ូវពិតជាដឹងគ្រប់យ៉ាងអំពីគាត់មិនថាគាត់នៅឆ្ងាយពីទ្រង់យ៉ាងណាក៏ដោយ។ ក្នុងព្រះគម្ពីរ **យ៉ូហាន ១៖៤៩** " ណាថាណែលក៏ទូលទ្រង់ថា លោកគ្រូ លោកជាព្រះរាជ-បុត្រានៃព្រះ លោកប្រាកដជាស្ដេចនៃសាសន៍អ៊ីស្រាអែលមែន" ។

ព្រះយេស៊ូវមិនត្រឹមតែស្គាល់ឈ្មោះរបស់អ្នកប៉ុណ្ណោះទេ។ ទ្រង់ដឹងគ្រប់យ៉ាងអំពីអ្នកទៀតផង។ អ្នកប្រហែលជាគិតថាអ្នកមិនសំខាន់ ហើយថាព្រះយេស៊ូវប្រហែលជាមិនស្គាល់អ្នកនោះទេ។ ប៉ុន្តែ អ្នកមានសារៈសំខាន់ខ្លាំងណាស់ចំពោះព្រះយេស៊ូវ ដោយសារទ្រង់បានបង្កើតអ្នកមក។ ព្រះគម្ពីរចែងថាទ្រង់បានស្គាល់អ្នកមុនអ្នកមកចាប់កំណើតនៅក្នុងផ្ទៃម្ដាយ (**ទំនុកដំកើង ១៣៩៖១៣-១៦**)។ទ្រង់ជ្រាបការដែលទូលបង្គំអង្គុយចុះនិងការដែលទូលបង្គំក្រោកឡើងផង ហើយមុនពេល មានពាក្យសំដីនៅលើអណ្តាតរបស់អ្នកទ្រង់ជ្រាបនូវអ្វីដែលអ្នកកំពុងគិតផង (**ទំនុកដំកើង ១៣៩៖២-៣**)។ ទ្រង់ទតឃើញតាមរយៈអ្នកសូម្បីទាំងសក់ក្បាលរបស់អ្នករាល់គ្នា ក៏ទ្រង់បានរាប់ទាំងអស់ដែរ (**លូកា ១២៖៧**)។

សូម្បីតែនៅពេលដែលអ្នកមិនអាចមានអារម្មណ៍ថាមានព្រះវត្តមាន ឬសេចក្តីស្រឡាញ់របស់ទ្រង់ក៏ដោយក៏ព្រះតែងតែនៅជាមួយអ្នក ហើយស្រឡាញ់អ្នក។ នេះមានន័យថា អ្នកតែងតែអាចងាកទៅរកព្រះយេស៊ូវដើម្បីសុំជំនួយ ដោយសារទ្រង់ស្គាល់អ្នក។ វាក៏មានន័យថាអ្នកអាចប្រាកដចិត្តថា ព្រះយេស៊ូវនឹងដឹកនាំអ្នកក្នុងទិសដៅត្រឹមត្រូវ។ សូមជឿថាព្រះយេស៊ូវដែលដឹងអ្វីៗទាំងអស់អំពីអ្នក ទ្រង់មានផែនការពិសេសសម្រាប់អ្នក!

## ៦. សំនួរពិភាក្សា

១.តើនរណាជាអ្នកប្រាប់ណាថាណែលអំពីព្រះយេស៊ូវ? *( ភីលីព)*

២. តើអ្វីដែលបានធ្វើឲ្យណាថាណែលទទួលជឿព្រះយេស៊ូវ? *(មុនដែលភីលីពហៅមក កាលអ្នកនៅក្រោមដើមល្វានៅឡើយ នោះខ្ញុំបានឃើញអ្នកហើយ)*

៣.តើព្រះបានដឹងអ្វីខ្លះអំពីអ្នក? *(គ្រប់យ៉ាង)*

**៧. ល្បែងកំសាន្ត « ឆ្វេងនិងស្តាំ»**



១. ឲ្យកុមារឈរជាជួរ គ្រូជាអ្នកស្រែកបញ្ជា ហើយកុមារលោតតាមការស្រែករបស់គ្រូ

២. គ្រូត្រូវស្រែកប្រាប់កុមារឲ្យធ្វើតាមពាក្យរបស់គាត់បើគ្រូ ស្រែកថាស្តាំ កុមារត្រូវលោតទៅស្តាំ បើគ្រូស្រែកថាឆ្វេង កុមារត្រូវលោតទៅឆ្វេង បើគ្រូស្រែកថាទៅក្រោយ កុមារត្រូវលោតទៅក្រោយ ហើយបើគ្រូស្រែកថាទៅមុខ កុមារត្រូវលោតទៅមុខ។

៣. សូមលេងម្តងទៀត មុនពេលចាប់ផ្តើមលេង ម្តងនេះកុមារត្រូវស្តាប់ឲ្យជាក់ ព្រោះកុមារត្រូវលោតផ្ទុយនិងពាក្យ ដែលគ្រូស្រែក ប្រសិនបើគ្រូស្រែកថាលោតទៅមុខ កុមារត្រូវលោតទៅក្រោយ គ្រូស្រែកលោតទៅឆ្វេង កុមារត្រូវលោតទៅស្តាំ គ្រូស្រែកឲ្យកាន់តែលឿន បើកុមារលោតខុសឲ្យគាត់អង្គុយចុះ។

៤. បន្ទាប់ពីលេងល្បែងចប់សូមពន្យល់កុមារថា ពេលខ្លះយើងច្រលំពីអ្វីដែលយើងត្រូវធ្វើ តែព្រះដឹងគ្រប់យ៉ាងពីយើង ហើយព្រះអង្គតែងតែជួយដល់យើង។

**៨. ខគម្ពីរចងចាំ**

**ទំនុកដំកើង ១៣៩៖១** *“ឱព្រះយេហូវ៉ាអើយទ្រង់បានពិនិត្យមើល ហើយបានស្គាល់ទូលបង្គំផង”*។

**៩. ហត្ថកម្ម**

សូមផាត់ពណ៌ “ព្រះយេស៊ូវស្គាល់ខ្ញុំហើយទ្រង់ស្រលាញ់ខ្ញុំ” ។

**១០. ចំរៀង** *(រើសចំរៀងខាងលើ១បទហើយច្រៀងជាមួយសិស្ស)*

**១១. អធិស្ឋាន**

**ការថ្វាយបង្គំសំរាប់គ្រូ៖ (សូមអាន ហើយអធិស្ឋានមុនពេលចាប់ផ្តើមបង្រៀន)**
ព្រះយេស៊ូវជ្រាបគ្រប់យ៉ាងអំពីអ្នក។ នេះមានន័យថាទោះបីជាអ្នកមានបញ្ហា ឬឧបសគ្គយើងអាចងាកបែរទៅរកព្រះដើម្បីសុំជំនួយ ដោយសារទ្រង់ដឹងពីអ្វីដែលអ្នកត្រូវការ និងរបៀបដែល ទ្រង់អាចជួយអ្នកបាន។ សូមសញ្ជឹងគិតអំពី ចំណុចនេះ ហើយមើលថាតើអ្នកត្រូវការជំនួយអ្វីពីព្រះនៅថ្ងៃនេះ ហើយអធិស្ឋានទៅព្រះអង្គ។

# ព្រះយេស៊ូវស្គាល់ខ្ញុំហើយទ្រង់ស្រលាញ់ខ្ញុំ!



សូមសរសេរខគម្ពីរចងចាំៈ______________________________

______________________________________________________

______________________________________________________

______________________________________________________

______________________________________________________